**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Oct-2015, 09:38
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**សេចក្ដីសង្ខេបរបស់មេធាវីការពារក្ដី លោក ខៀវ សំផន ពាក់ព័ន្ធនឹងការទទួលយកប្រតិចារឹក ផ្ដល់ដោយលោក Robert LEMKIN**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Chandra Nihal JAYASINGHE

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

កញ្ញា Cécile ROUBEIX

កញ្ញា អ៊ូច ស្រីផាត់

លោក Arnaud RIVOAL

កញ្ញា Marine BOUDJEMAA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដី លោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូល (“តុលាការកំពូល”) បានបង្គាប់ឱ្យមានការស៊ើបសួរបន្ថែម ដែលមានគោលបំណងចម្បងដើម្បីអាចកំណត់មើលថា តើផ្នែកនៃឯកសារវីដេអូដែលលោក Robert LEMKIN និងលោក ថេត សម្បត្តិ មាននោះ អាចត្រូវផ្តល់ជូនតុលាការក្នុងរយៈពេលមួយសមស្របបានដែរឬទេ ហើយដើម្បីអាចវាយតម្លៃបានថា តើគេអាចទាញយកព័ត៌មានអ្វីខ្លះពីឯកសារមួយនេះ[1]។

២. ក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរបន្ថែមនេះ ចៅក្រមរបាយការណ៍នៃតុលាការកំពូល បានស្តាប់ចម្លើយលោក Robert LEMKIN[2] ហើយដែលនៅពេលក្រោយមកទៀត លោក Robert LEMKIN បានផ្តល់អត្ថបទដកស្រង់ពីអត្ថបទមួយដែលនឹងត្រូវចេញផ្សាយ ដោយអត្ថបទនោះបានសង្ខេបពីខ្លឹមសារនៃកិច្ចសម្ភាសមួយចំនួនជាមួយនឹងមនុស្សបួននាក់ (“កំណត់ហេតុ”)[3] ហើយក្រោយមកទៀតគាត់បានផ្តល់ប្រតិចារឹកនៃកិច្ចសម្ភាសទាំងអស់នោះ (“ប្រតិចារឹក”)[4]។

៣. នៅថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ តុលាការកំពូលបានផ្តល់ប្រតិចារឹកជូនភាគី និងស្នើឱ្យភាគីផ្តល់យោបល់ពាក់ព័ន្ធនឹងការទទួលយកប្រតិចារឹកទាំងអស់នោះទាំងស្រុង ឬក៏មួយផ្នែកណាមួយ មកធ្វើជាភ័ស្តុតាង[5]។

---

[1] សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **F2/4/3** កថាខណ្ឌ ២៤ និង ២៥។

[2] កំណត់ហេតុស្តាប់ចម្លើយសាក្សី Robert T.F. LEMKIN ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/1**។

[3] កំណត់ហេតុរបស់ Robert LEMKIN ទៅលើកម្មវិធីនយោបាយរបស់ រស់ ញឹម ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/3.1** (“កំណត់ហេតុ”)។

[4] *ប្រតិចារឹកនៃកិច្ចសម្ភាសផ្តល់ដោយ Robert LEMKIN* ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/3/6.2** (“ប្រតិចារឹក”)។

[5] សេចក្តីសម្រេចស្នើឱ្យដាក់សារណា ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/3/6**។

៤. តាមរយៈសារណានេះ មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") សូមបញ្ជាក់ថាខ្លួនយល់ឃើញថា ត្រូវតែទទួលយកប្រតិចារឹកទាំងអស់នោះទាំងស្រុងមកធ្វើជាភ័ស្តុតាង។

៥. ប្រតិចារឹកទាំងអស់នោះ បំពេញបានគ្រប់ល័ក្ខខ័ណ្ឌតម្រូវដើម្បីអាចទទួលយកធ្វើជាភ័ស្តុតាង ស្របតាមវិធាន ១០៤ ១) និង វិធាន ១០៨ ៧) នៃវិធានផ្ទៃក្នុង។ ប្រតិចារឹកទាំងអស់នោះអាចរកបានភ្លាមៗ ហើយមិនមានមូលហេតុនៃភាពមិនអាចទទួលយកបានណាមួយ ដូចមានចែងក្នុងវិធាន ៨៧ ៣) អាចយកមកអនុវត្តបានទៅលើប្រតិចារឹកទាំងអស់នោះបានទេ។

៦. ជាបឋម ប្រតិចារឹកទាំងអស់នោះអាចឱ្យគេវាយតម្លៃបានពីភាពពាក់ព័ន្ធ ភាពទុកចិត្ត និងភាពជឿជាក់បាននៃភ័ស្តុតាងផ្សេងៗទៀតដែលបានស្នើសុំ ឬក៏ត្រូវបានបង្ហាញនៅចំពោះមុខតុលាការកំពូល (កំណត់ហេតុស្ដាប់ចម្លើយលោក Robert LEMKIN កំណត់ហេតុលោក Robert LEMKIN សក្ខីកម្មសាក្សីម្នាក់ក្នុងចំណោមសាក្សីផ្សេងទៀតដែលត្រូវបានស្ដាប់ចម្លើយអំឡុងពេលសវនាការក្នុងខែ កក្កដា ឆ្នាំ ២០១៥[6] ការកោះហៅសាក្សីមួយចំនួនស្នើសុំដោយមេធាវីការពារក្ដី លោក នួន ជា[7])។

៧. បន្ទាប់មក ប្រតិចារឹកទាំងអស់នោះមានផលវិបាកលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទទាំងពីររូប និងអាចធ្វើឱ្យលទ្ធផលនៃការជំនុំជម្រះប្រែប្រួល។ ក្រោយពីបានអានយ៉ាងលឿននូវប្រតិចារឹកទាំងអស់នោះរួចមក[8] គេឃើញថាខ្លឹមសារនៃប្រតិចារឹកពាក់ព័ន្ធនឹងការបែកបាក់គ្នាក្នុងជួរថ្នាក់ដឹកនាំបក្ស ក៏ដូចជាសកម្មភាពមួយចំនួនដែលត្រូវបានធ្វើឡើងក្នុងបំណងផ្ដួលរំលំ ប៉ុល ពត ដូចដែលតុលាការកំពូលបានធ្វើការគូសបញ្ជាក់[9]។

---

[6] សេចក្ដីសម្រេចបណ្ដោះអាសន្នលើកទីបីស្ដីពីកិច្ចស៊ើបសួរបន្ថែម ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/3/5** ទំព័រ ៤ កំណត់សម្គាល់ជើងទំព័រ ១៥។

[7] ដូចយោងខាងលើ ទំព័រ ៤ កំណត់សម្គាល់ជើងទំព័រ ១៦។

[8] ដោយពិនិត្យលើពេលវេលាដែលបានផ្ដល់ជូនសម្រាប់ដាក់សារណា (និងសេចក្ដីបញ្ជាក់របស់អង្គជំនុំជម្រះតុលាការកំពូលថាខ្លួនមិនចង់ពន្យារពេលបន្ថែម) មេធាវីការពារក្ដីមិនអាចពិនិត្យមើលឱ្យបានស៊ីជម្រៅទៅលើប្រតិចារឹកដែលមាន ១៩០ ទំព័រ ជាភាសាអង់គ្លេសបានទេ។

[9] សេចក្ដីសម្រេចស្នើឱ្យដាក់សារណា ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ **F2/4/3/3/6** ទំព័រ ៣-៥។

៨. ការបែកបាក់ និងសកម្មភាពទាំងអស់នោះ ត្រូវបានអនុវត្តដោយបុគ្គលមួយចំនួន[10] ដែលអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានកំណត់ថាជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ជាមួយនឹង ប៉ុល ពត នួន ជា និង ខៀវ សំផន ដែលអ្នកទាំងអស់នេះមានផែនការរួមតែមួយ "*ដែលបានរៀបចំឡើងដោយហ្មត់ចត់*" យ៉ាងយូរបំផុតនៅខែ មិថុនា ឆ្នាំ ១៩៧៤ ហើយដែល "*ផែនការនេះបានបន្តយ៉ាងហោចណាស់ដល់ខែ ធ្នូ ឆ្នាំ ១៩៧៧*"[11]។ អង្គជំនុំជម្រះយល់ឃើញថា អ្នកទាំងអស់នេះអាចជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្ត ព្រោះពួកគាត់បានធ្វើសកម្មភាពដើម្បីចូលរួមក្នុងផែនការរួម[12] ដែលការយល់ឃើញបែបនេះបាននាំឱ្យលោក ខៀវ សំផន ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយសារតែផែនការសហឧក្រិដ្ឋកម្មរួម[13]។ ក៏ប៉ុន្តែ ប្រតិចារឹកបានបង្ហាញថា បុគ្គលទាំងអស់នេះមិនមានចេតនាដូចគ្នានោះទេ ហើយសកម្មភាពរបស់ពួកគាត់ទៀត ក៏មិនស្ថិតក្នុងក្របខណ្ឌនៃផែនការរួមដែលបានលើកឡើងនោះដែរ។

៩. លើសពីនេះទៀត តាមរយៈការអានប្រតិចារឹកទាំងអស់នោះរួចមក គេឃើញថាវាមានភាពផ្ទុយគ្នាពីការអះអាងរបស់អង្គជំនុំជម្រះ[14] ព្រោះថារាល់សេចក្តីសម្រេចពុំត្រូវបានធ្វើជាសមូហភាពនោះទេ គឺ ប៉ុល ពត ទេដែលជាអ្នកសម្រេចតែម្នាក់ឯង ដោយមិនមានការព្រមព្រៀងគ្នាឱ្យបានច្រើន និងទោះបីជាមានការមិនការឯកភាពជាទូទៅក៏ដោយ។ ក៏ប៉ុន្តែ ការកំណត់និយមន័យមិនត្រូវត្រឹមរបស់អង្គជំនុំជម្រះចំពោះពាក្យ "ប្រជាធិបតេយ្យប្រមូលផ្តុំ" បាននាំឱ្យអង្គជំនុំជម្រះយល់ឃើញថា លោក ខៀវ សំផន អាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ[15] ដែលការយល់ឃើញបែបនេះផ្ទុយពីការពិត។

---

[10] យ៉ាងហោចណាស់ រស់ ញឹម សោ ភឹម និង វ៉ន វ៉េត។

[11] សាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** ("សាលក្រម") កថាខណ្ឌ ៧៧៧ និង ៧៧៨។

[12] សាលក្រម កថាខណ្ឌ ៨០៧, ៨១០, ៨៣៦។

[13] សាលក្រម កថាខណ្ឌ ៩៦៣។

[14] សាលក្រម កថាខណ្ឌ ២២៨។

[15] សាលក្រម កថាខណ្ឌ ៩៩៧, ៩៩៩, ១០០៦, ១០១៤, ១០៣១។

១០. ក្រៅពីនេះ ប្រតិចារឹកបានបញ្ជាក់ពីអវត្តមាននៃការឯកភាពគ្នាក្នុងជួរកងទ័ព និងភាពផ្ទុយគ្នារវាងសេចក្តីណែនាំផ្សេងៗចេញដោយថ្នាក់ដឹកនាំនៅទីក្រុងភ្នំពេញ និងតថភាពជាក់ស្តែងនៅតាមមូលដ្ឋាន ដែលគ្រប់គ្រងដោយប្រធានភូមិភាគ។ ផ្ទុយពីការអះអាងរបស់អង្គជំនុំជម្រះ[16] ប្រធានភូមិភាគទាំងអស់នោះអាចធ្វើការបានដោយឯករាជ្យម្ចាស់ការដោយ ប៉ុល ពត មិនបានដឹង និងទោះបីជាពួកគេមានទំនាក់ទំនងស្អិតរមួតជាមួយគ្នា[17] ហើយបើទោះបីជា ប៉ុល ពត បានដឹង ក៏គាត់បានត្រឹមតែបញ្ជូនមនុស្សឲ្យទៅធ្វើការស៊ើបអង្កេតតែប៉ុណ្ណោះ។ ប្រតិចារឹកទាំងអស់នោះក៏បានបង្ហាញផងដែរថា "ការណ៍ដែលបាននៅជិត" ប៉ុល ពត ក៏ដូចជាវត្តមានក្នុងកិច្ចប្រជុំនានា ក៏មិនអាចមានន័យបានថាជាការចូលរួម ឬក៏ជាការចែករំលែកព័ត៌មាននោះដែរ។ អង្គជំនុំជម្រះបានសំអាងដោយមិនត្រឹមត្រូវលើមូលដ្ឋានធាតុផ្សំទាំងអស់នេះ ដើម្បីបង្ហាញពីការដឹងឮរបស់លោក ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្ត និងការចូលរួមរបស់គាត់[18]។

១១. **<u>ផ្អែកតាមសម្អាងហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំឲ្យតុលាការកំពូលមេត្តាទទួលយកប្រតិចារឹកទាំងអស់នោះធ្វើជាភ័ស្តុតាង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |

[16] សាលក្រម កថាខណ្ឌ ៨៥៩ និង ៨៦០។

[17] ឧទាហរណ៍ សាលក្រម កថាខណ្ឌ ៧៧៧ កំណត់សម្គាល់ជើងទំព័រ ២៤៥១, ២៤៥៣, ២៤៥៤។

[18] សាលក្រម កថាខណ្ឌ ៤០៨-៤០៩, ៩៥៣, ៩៥៤, ៩៦៧, ៩៧៦, ៩៩៤-៩៩៥, ១០១២, ១០២១, ១០២៨, ១០៣៥, ១០៣៩, ១០៤១, ១០៤៥, ១០៤៩-១០៥០។